ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងព័ត៌មាន | ក្រសួងកិច្ចការនារី | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# សេចក្តីណែនាំ
# ស្តីពី
# ការហាមឃាត់ការផលិត ផ្សព្វផ្សាយ និងចែកចាយបន្តនូវមាតិកា ដែលប៉ះពាល់ដល់វប្បធម៌ ប្រពៃណីជាតិ ទំនៀមទម្លាប់ កិត្តិយស សេចក្តីថ្លៃថ្នូរ និងតម្លៃស្ត្រីខ្មែរ

ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានពិនិត្យឃើញថា កន្លងមកក្រសួងព័ត៌មានធ្លាប់បានផ្តល់នូវសេចក្តីណែនាំដល់អ្នកផលិតមាតិកាផ្សព្វផ្សាយតាមបណ្តាញទំនាក់ទំនងសង្គម ដោយផ្តោតការផលិត និងការចែកចាយប្រកបដោយការទទួលខុសត្រូវ ដើម្បីរក្សាបាននូវសណ្តាប់ធ្នាប់សង្គម។ ប៉ុន្តែបច្ចុប្បន្ននេះ មានអ្នកផលិតមាតិកាមួយចំនួនបានបំពានសេចក្តីណែនាំ ក្រមសីលធម៌ និងមនសិការវិជ្ជាជីវៈ ឬខ្វះការពិចារណាក្នុងការថែរក្សាវប្បធម៌ ប្រពៃណី អត្តសញ្ញាណជាតិខ្មែរ និងជាពិសេសការលើកតម្កើងសេចក្តីថ្លៃថ្នូរនិងកិត្តិយសរបស់ស្ត្រី ដោយបានផលិត ផ្សព្វផ្សាយ និងចែកចាយបន្តនូវមាតិកាដែលប្រើប្រាស់ពាក្យសម្តីអសុរោះ អសីលធម៌ និងប្រើប្រាស់រូបរាងកាយស្ត្រីបង្ហាញរូបភាពអនាចារនិងស្រើបស្រាល ដើម្បីតែស្វែងរកការចាប់អារម្មណ៍និងបម្រើផលប្រយោជន៍ផ្ទាល់ខ្លួន ឬបម្រើឱ្យការលក់ផលិតផលរបស់ខ្លួន ដែលនាំឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វប្បធម៌ ប្រពៃណី និងសីលធម៌សង្គមជាតិខ្មែរ។

ការផលិត ចែកចាយ និងផ្សព្វផ្សាយបន្តនូវមាតិកាទាំងនេះ បណ្តាលឱ្យជះឥទ្ធិពលអវិជ្ជមានដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រីខ្មែរ ជាពិសេសធ្វើឱ្យប៉ះពាល់ដល់គុណតម្លៃដ៏ផូរផង់នៃវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ ដែលបុព្វបុរសខ្មែរបានខិតខំថែរក្សា និងលើកតម្កើងតាំងពីយូរលង់ណាស់មកហើយ។ ការចម្លងគម្រូវប្បធម៌បរទេសតាមរយៈការយកស្ត្រីជាកម្មវត្ថុនៃការបង្ហាញកេរ្តិ៍ខ្មាស និងភាពស្រើបស្រាលត្រូវចៀសវាងជាដាច់ខាត ព្រោះនេះជាការទម្លាក់នូវគុណតម្លៃ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រី និងជាការប្រាសចាកប្រពៃណី និងវប្បធម៌កម្ពុជា ដែលអាចនាំដល់ការធ្លាក់ចុះនៃសីលធម៌ និងការយល់ដឹងអំពីអត្តសញ្ញាណជាតិខ្មែរ ក្នុងចំណោមយុវជននិងយុវតីជំនាន់ក្រោយ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងបណ្តាញទំនាក់ទំនងសង្គម។

ដើម្បីលើកកម្ពស់វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងសីលធម៌ដ៏ល្អផូរផង់របស់ជាតិខ្មែរ ជាពិសេសថែរក្សាកិត្តិយស សេចក្តីថ្លៃថ្នូរ និងគុណតម្លៃស្ត្រី ក្នុងបរិបទនៃការរីកចម្រើនផ្នែកបច្ចេកវិទ្យាឌីជីថល និងប្រព័ន្ធផ្សព្វផ្សាយ ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមណែនាំដល់អ្នកផលិតមាតិកា អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម អ្នកសារព័ត៌មានប្រជាជន និងប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទទាំងអស់ ដូចខាងក្រោម៖

១- បញ្ឈប់រាល់ការផលិត ផ្សព្វផ្សាយ និងចែកចាយបន្តគ្រប់រូបភាព សារជាអក្សរ/សំឡេង វីដេអូ ឬមាតិកាទាំងឡាយណាដែលប្រើប្រាស់ពាក្យសម្តីអសុរោះ ជេរប្រមាថ និងបង្ហាញកេរ្តិ៍ខ្មាស និងភាពស្រើបស្រាល ដូចជាការស្លៀកពាក់ខើចលើខើចក្រោមជ្រុលហួសហេតុពេក កាយវិការត្រាប់តាមសកម្មភាព អាសអាភាស និងអំពើហិង្សាផ្ទុយនឹងសីលធម៌ប្រពៃណីខ្មែរ។

២- បញ្ឈប់រាល់ការយករូបរាងកាយស្ត្រី និងសកម្មភាពពាក់ព័ន្ធនឹងស្ត្រី ដែលមានលក្ខណៈអនាចារ និងស្រើបស្រាល មកធ្វើជាឧបករណ៍សម្រាប់ទាក់ទាញការចូលចិត្ត ការចែករំលែកបន្ត និងការចូលមើល (Likes, Shares, Views) នូវមាតិការបស់ខ្លួន ឬមកភ្ជាប់នឹងការផ្សាយពាណិជ្ជកម្មផលិតផល ដើម្បីបម្រើឱ្យផលប្រយោជន៍បក្ខពួក ឬផលប្រយោជន៍ផ្ទាល់ខ្លួន។

៣- សូមចូលរួមផលិត ផ្សព្វផ្សាយ និងចែកចាយបន្តនូវមាតិកាដែលបង្ហាញអំពីខ្លឹមសារ សកម្មភាព និងរូបភាពនានាដើម្បីចូលរួមថែរក្សាវប្បធម៌ ប្រពៃណីជាតិខ្មែរ និងការលើកតម្កើងកិត្តិយស និងគុណតម្លៃរបស់ស្ត្រីខ្មែរឱ្យបានទូលំទូលាយ និងបង្ហាញនូវការលើកកម្ពស់តួនាទីស្ត្រីនៅក្នុងសង្គម និងនៅលើឆាកអន្តរជាតិ។

៤- រាល់ការផ្សាយពាណិជ្ជកម្មផលិតផល ឬសេវាកម្មនានា ត្រូវចៀសវាងដាច់ខាតនូវការប្រើប្រាស់រូបភាព ឬភាសាដែលបង្កប់នូវការរើសអើងភេទ និងការបំពានលើសេចក្តីថ្លៃថ្នូររបស់ស្ត្រី និងមនុស្សគ្រប់ៗរូប។

៥- អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម អ្នកសារព័ត៌មានប្រជាជន និងអ្នកសារព័ត៌មានគ្រប់ៗរូប ត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ និងវិជ្ជាជីវៈសារព័ត៌មាន និងត្រូវគោរពច្បាប់ជាធរមាន ដោយមិនត្រូវផលិត ផ្សព្វផ្សាយ និងចែករំលែកបន្តនូវមាតិកាដែលជះឥទ្ធិពលអវិជ្ជមានដល់តម្លៃស្ត្រី។

៦- សូមជំរុញ និងលើកទឹកចិត្តដល់ការផលិតមាតិកា ដែលបង្ហាញពីភាពច្នៃប្រឌិត ការអប់រំ បំណិនជីវិត សិល្បៈ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ជាតិខ្មែរ ដើម្បីចូលរួមកសាងសង្គមមួយដែលមានចំណេះដឹង និងប្រកបដោយសីលធម៌ និងអរិយធម៌ខ្ពង់ខ្ពស់ ក៏ដូចជាការលើកកម្ពស់សមភាពយេនឌ័រនៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន និងទៅអនាគត។

ក្រសួងព័ត៌មាន ក្រសួងកិច្ចការនារី និងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមជម្រាបដល់អ្នកផលិតមាតិកា អ្នកប្រើប្រាស់បណ្តាញទំនាក់ទំនងសង្គម អ្នកសារព័ត៌មានប្រជាជន និងប្រព័ន្ធផ្សព្វផ្សាយគ្រប់ប្រភេទ សូមចូលរួមសហការអនុវត្តតាមសេចក្តីណែនាំនេះ ដោយត្រូវប្រកាន់ខ្ជាប់នូវក្រមសីលធម៌ វិជ្ជាជីវៈសារព័ត៌មាន និងសុជីវធម៌សង្គម ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ជាតិ និងការលើកកម្ពស់តួនាទីស្ត្រីនៅក្នុងសង្គមជាតិ។

ក្រសួងនឹងចាត់វិធានការយ៉ាងតឹងរឹងតាមច្បាប់ចំពោះនីតិបុគ្គល ឬរូបវន្តបុគ្គលដែលនៅតែបន្តផលិត ផ្សព្វផ្សាយ និងចែកចាយបន្តនូវមាតិកាដែលផ្ទុយនឹងខ្លឹមសារនៃសេចក្តីណែនាំនេះ ក្រោយទទួលវិធានការអប់រំ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២ ខែមេសា ឆ្នាំ២០២៦

**ក្រសួងព័ត៌មាន** **ក្រសួងកិច្ចការនារី** **ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**





